CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសពត៌មាន**

ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

ទំនាក់ទំនង: Jennifer Songster, បណ្ណាល័យសាធារណៈឡុងប៊ិច (Long Beach Public Library), 562.570.6860, Jennifer.Songster@longbeach.gov

សម្រាប់ការផ្សព្វផ្សាយបន្ទាន់

# បណ្ណាល័យសាធារណៈឡុងប៊ិច បន្ថែមកាតាឡុក/បញ្ជីឈ្មោះសៀវភៅជាភាសាខ្មែរ ទៅក្នុងការស្វែងរកតាមអ៊ីនធឺណិត

ក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - បណ្ណាល័យសាធារណៈឡុងប៊ិច (LBPL) បានបន្ថែមសមត្ថភាពនៃការស្វែងរកជាភាសារខ្មែរ ទៅក្នុងកាតាឡុក/បញ្ជីឈ្មោះសៀវភៅ តាមអ៊ីនធឺណិតរបស់ខ្លួន។ ជាមួយនឹងមុខងារថ្មីនេះ, រកឃើញតាមរយៈកាតាឡុកតាមអ៊ីនធឺណិត នៅលើគេហទំព័រ longbeach.gov/library, អ្នកអាន អាចស្វែងរកអ្នកនិពន្ធ, ចំណងជើង, ឬមុខវិជ្ជាជាភាសាខ្មែរ ដើម្បីស្វែងរកចំណងជើងជាភាសាខ្មែរ ដែលមានទីតាំងនៅក្នុងបណ្ណាល័យ។

អភិបាលក្រុងលោក Robert Garcia មានប្រសាសន៍ថា "ក្រុងឡុងប៊ិចមានការប្តេជ្ញាចិត្ត ក្នុងការធ្វើអោយទទួលបាននូវព័ត៌មានប្រកបដោយសមធម៌ ហើយយើងមានមោទនភាពដែលធ្វើឱ្យមើលឃើញកាន់តែច្បាស់ នូវការប្រមូលផ្តុំជាភាសាខ្មែរកាន់តែច្រើនឡើង តាមរយៈមុខងារថ្មីនេះ,"។ "ឥឡូវនេះ ច្រើនជាងពេលណាៗទាំងអស់, វាមានសារៈសំខាន់ណាស់ ដែលជនជាតិអាស៊ីអាមេរិកាំងនៅទូទាំងសហគមន៍របស់យើង ត្រូវបានគេមើលឃើញ និងឮសំឡេង។ ការកែលំអរធ្វើអោយប្រសើរឡើងនូវការចូលប្រើប្រាស់សំភារៈបណ្ណាល័យជាភាសាខ្មែរ

គឺគ្រាន់តែជាវិធីមួយដែលយើងទទួលស្គាល់ នូវការចូលរួមវិភាគទានជាច្រើនទសវត្សរបស់សហគមន៍ខ្មែរ នៅក្នុងទីក្រុងដ៏អស្ចារ្យរបស់យើង"។

សមត្ថភាពក្នុងការស្វែងរកភាសាខ្មែរ បានផ្តល់មូលនិធិដោយជំនួយលើច្បាប់សេវាកម្មបណ្ណាល័យ និងបច្ចេកវិទ្យា (Library Services and Technology Act) ដែលគ្រប់គ្រងដោយបណ្ណាល័យរដ្ឋកាលីហ្វ័រញ៉ានៅឆ្នាំ ២០១៨ និងត្រូវបានសាកល្បងដោយយូស៊ីស៊ី ឬសហគមន៍ខ្មែរ (United Cambodian Community)។ សរុបបញ្ចូលគ្នា LBPL មានសៀវភៅសំរាប់មនុស្សពេញវ័យ និងកុមារប្រមាណ ៥,000 ក្បាល។ កាលពីមុន, ដើម្បីស្វែររកសៀវភៅបណ្ណាល័យដែល ត្រូវបានដាក់ជាកាតាឡុក/បញ្ជីឈ្មោះសៀវភៅជាភាសាមួយផ្សេងទៀត (លើកលែងតែភាសាអេស្ប៉ាញ), ភ្ញៀវត្រូវស្វែងរកកាតាឡុកបណ្ណាល័យជាភាសាអង់គ្លេស ជាមុនសិន។ ជាមួយនឹងមុខងារថ្មី, ឥឡូវនេះ អ្នកអានអាចស្វែងរកអក្សរសាស្រ្តជាភាសាខ្មែរ ដោយផ្ទាល់។

លោក Glenda Williams នាយកផ្នែកសេវាកម្មបណ្ណាល័យ មានប្រសាសន៍ថា “បណ្ណាល័យសាធារណៈនៅឡុងប៊ិចមានការប្រមូលឯកសារផ្ដុំជាភាសាខ្មែរច្រើនជាងគេ នៅក្នុងបណ្ណាល័យសាធារណៈនៅសហរដ្ឋអាមេរិក,”។ “មុខងារបន្ថែមនេះ ធ្វើឱ្យមាននូវសៀវភៅទាំងនោះ សម្រាប់អ្នកអានជាភាសាខ្មែរ, ដូចគ្នាទៅនឹងសៀវភៅភាសាអង់គ្លេស ដែលមានសម្រាប់អ្នកអានជាភាសាអង់គ្លេសដែរ។ លើសពីនេះទៀត, ប្រជាពលរដ្ឋអាចរក្សាទុកឬកក់សម្ភារៈជាភាសារខ្មែរ តាមរយៈកាតាឡុកតាមអ៊ីនធឺរណិតរបស់បណ្ណាល័យ,”។

ភាសាខ្មែរ គឺជាភាសាផ្លូវការរបស់ប្រទេសកម្ពុជា និងជាភាសានិយាយជាទូទៅបំផុត ដោយប្រជាជនដើមកំណើតខ្មែរ។ ក្រុងឡុងប៊ិចមានប្រជាជនកម្ពុជា និងកម្ពុជាអាមេរិកាំងច្រើនជាងគេបំផុត នៅសហរដ្ឋអាមេរិក។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើន បានភៀសខ្លួនពីប្រទេសកម្ពុជា ទៅកាន់សហរដ្ឋអាមេរិកនៅដើមទសវត្សឆ្នាំ ១៩៨០, ដោយមានជនភៀសខ្លួនមួយចំនួនធំ មកតាំងទីលំនៅនៅទីនេះ។

## អំពីទីក្រុងឡុងប៊ិច

មានប្រជាជនប្រមាណ ៤៧០,០០០ នាក់, ទីក្រុងឡុងប៊ិច គឺទទួលបាននូវពានរង្វាន់ជាច្រើន និងមានការច្នៃប្រឌិត ផ្តល់នូវភាពសំបូរបែបដែលជាលំដាប់ទីក្រុងធំមួយរបស់ពិភពលោក ខណៈពេលដែលរក្សាបាននូវអារម្មណ៍ជាលក្ខណៈបុគ្គល និងសង្កាត់ផ្សេងៗគ្នាដែលមានភាពចំរុះជាតិសាសន៍ រស់នៅជុំគ្នានៅតាមឆ្នេរសមុទ្រកាលីហ្វ័រញ៉ា។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញ, ទីក្រុងឡុងប៊ិចជាផ្ទះរបស់កប៉ាល់ម្ចាស់ក្សត្រី Queen Mary, អាងចិញ្ចឹមត្រី នៃមហាសមុទ្រប៉ាស៊ីហ្វិក, សារៈមន្ទីរ និងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានគេវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច, ក៏ដូចជាការឈ្នះពានរង្វាន់ជាច្រើនផងដែរ នៃក្រសួង/នាយកដ្ឋាននានារបស់ទីក្រុង ដូចជាក្រសួងសុខាភិបាល, សួនឧទ្យាន, ការកំសាន្តសប្បាយ និងសមុទ្រ, សេវាកម្មអភិវឌ្ឍន៍ និងជាច្រើនមុខទៀត។ ផងដែរ ទីក្រុងនេះក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យ ដែលទទួលបានការគោរពខ្ពស់, មានកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្រ្តចំនួន ២, មន្ទីរពេទ្យចំនួន ៥, កន្លែងហ្វឹកហាត់កូនហ្គោលចំនួន ៥ កន្លែង, សួនឧទ្យានចំនួន ១៧១ កន្លែង, ឆ្នេរខ្សាច់ជាច្រើនម៉ៃយ៍, កន្លែងចតកប៉ាល់កំសាន្តសមុទ្រជាច្រើនកន្លែង, ផ្លូវកង់ និងកម្មវិធីជិះកង់រួមគ្នា។

សម្រាប់ព័ត៌មានបន្ថែម អំពីទីក្រុងឡុងប៊ិច, សូមមើលគេហទំព័រ http://longbeach.gov/ ។ តាមមើលពួកយើងលើបណ្តាញសង្គម ដើម្បីតាមដានពត៌មានថ្មីៗ នៅតាមបណ្តាញ Facebook, Twitter, Instagram និង YouTube ។

## អំពីបណ្ណាល័យសាធារណៈឡុងប៊ិច

បណ្ណាល័យសាធារណៈឡុងប៊ិច, បង្កើតឡើងក្នុងឆ្នាំ ១៨៩៦, ដែលបម្រើដល់ទីក្រុងប្រជុំជនចម្រុះដែលមានប្រជាជនជិតកន្លះលាននាក់។ ប្រព័ន្ធបណ្ណាល័យសាធារណៈឡុងប៊ិច រួមមានបណ្ណាល័យ Billie Jean King Main Library និងបណ្ណាល័យសង្កាត់ចំនួន ១១ និងមានវត្តមាននៅលើអ៊ីនធឺណិត យ៉ាងរស់រវើក។ នៅរដូវក្តៅ ឆ្នាំ ២០១៧ បណ្ណាល័យសាធារណៈឡុងប៊ិច បានទទួលពានរង្វាន់ថ្នាក់ជាតិ ចំពោះសេវាកម្មបណ្ណាល័យ និងសារៈមន្ទីរ ដោយមានការទទួលស្គាល់នូវកិច្ចសហការរបស់សហគមន៍ ប្រកប ដោយភាពជោគជ័យ, បង្កើតនូវកម្មវិធី STEM (វិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម, និងគណិតវិទ្យា) និងកម្មវិធីនានា

ដែលផ្តោតអក្ខរកម្ម ជូនដល់ប្រជាពលរដ្ឋរស់នៅក្រុងឡុងប៊ិច។ ដោយផ្តោតលើការផ្តល់ព័ត៌មាន និងការគាំទ្រដោយឥតគិតថ្លៃ និងស្មើភាពគ្នា សម្រាប់ការរៀនសូត្រពេញមួយជីវិត, បណ្ណាល័យផ្តល់ជូននូវសៀវភៅ, ប្រព័ន្ធផ្សព្វផ្សាយ, មូលដ្ឋានទិន្នន័យ, ការចូលប្រើប្រាស់អ៊ីនធឺណិត, មជ្ឈមណ្ឌលសិក្សាជាលក្ខណៈគ្រួសារ, កន្លែងផលិតរបស់របរផ្សេងៗ, និងព្រឹត្តិការណ៍ជាច្រើនមុខផ្សេងទៀត រាប់ចាប់ពីពេលវេលានិទានរឿង រហូតដល់កម្មវិធីអប់រំ និងវប្បធម៌។

សម្រាប់ព័ត៌មានបន្ថែម, សូមចូលទៅកាន់គេហទំព័រ http://www.longbeach.gov/library, "ចូលចិត្ត" បណ្ណាល័យសាធារណៈឡុងប៊ិច នៅលើ Facebook, ហើយតាមដាន តាម Twitter និង Instagram ។

###